**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីណែនាំ

## ស្តីពី

## ការតម្រូវឱ្យបំពេញការងារពីផ្ទះតាមប្រព័ន្ធ Online សម្រាប់រយៈពេល ១ សប្តាហ៍

ប្រតិបត្តិតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងវិធានការចាំបាច់ជាអាទិភាពចំពោះមុខក្នុងការការពារ និងប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ដែលបាននិងកំពុងបន្តកើតមានជាបន្តបន្ទាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីព្រឹត្តិការណ៍ “**សហគមន៍ ២០ កុម្ភៈ ២០២១**” មក, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង, ប្រធានគ្រប់អង្គភាពដែលមានទីតាំងក្នុងទីស្តីការក្រសួង, ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, ឯកឧត្តមនាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លោក លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយព្រឹត្តិការណ៍ “**សហគមន៍ ២០ កុម្ភៈ ២០២១**” និងបុគ្គលិកមន្ត្រីរាជការនៃគ្រប់អង្គភាពដែលបានរៀបរាប់ខាងលើ **សូមបំពេញការងារពីផ្ទះតាមប្រព័ន្ធ Online សម្រាប់រយៈពេល ១ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះ រហូតដល់មានការណែនាំជាថ្មី។ ទន្ទឹមនេះ ចំពោះការិយាល័យ ឬអង្គភាពដែលទទួលបន្ទុកទទួលឯកសារ, ប្រធានអង្គភាពនីមួយៗ ត្រូវចាត់ចែងឱ្យមានមន្ត្រីផ្លាស់វេនគ្នាមកប្រចាំការក្នុងចំនួនកំណត់សមរម្យមួយ ដើម្បីបន្តនិរន្តរភាពកិច្ចការងាររដ្ឋបាលរបស់អង្គភាពខ្លួន។ បន្ថែមលើនេះ សូមមន្ត្រីរាជការទាំងអស់ ដែលចេញ-ចូលទីស្តីការក្រសួង ត្រូវបន្តអនុវត្តការស្កេន QR Code “ទប់ស្កាត់កូវីដ-១៩” ឱ្យបានខ្ជាប់ខ្ជួន និងជាប្រចាំ** ស្របតាមសេចក្តីជូនដំណឹងរបស់ក្រសួងនាពេលកន្លងទៅនេះ។

ចំពោះអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានរតនាគារជាតិ, ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ត្រូវគោរពតាមការណែនាំដោយផ្ទាល់របស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក្នុងការចាត់តាំងមន្ត្រីបម្រើការងារដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃការប្រមូលចំណូល ការផ្តល់សេវាជូនដល់ធុរជន និងការបើកផ្តល់ថវិកាសម្រាប់ការអនុវត្តការងាររបស់ស្ថាប័នរដ្ឋ។

ទទួលបានសេចក្តីណែនាំនេះ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង ប្រធានគ្រប់អង្គភាព និងបុគ្គលិកមន្ត្រីរាជការទាំងអស់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២១

**កន្លែងទទួល ÷**

- ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ នៃកសហវ
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ នៃកសហវ
- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ នៃកសហវ
- គ្រប់អង្គភាព ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន នៃកសហវ
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666